# ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦១៧

# ស្តីពី

# ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

---

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០២ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ហៅកាត់ថា "គ.ជ.ប.ទ"។

**មាត្រា ២._**

ព្រះរាជក្រឹត្យនេះ មានគោលដៅបង្ការ និងប្រឆាំងរាល់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីពង្រឹងកិច្ចការពារជនទាំងឡាយ ដែលត្រូវបានដកហូត សេរីភាពឲ្យរួចផុតពីការធ្វើទារុណកម្ម។

**មាត្រា ៣._**

សកម្មភាពរបស់ "គ.ជ.ប.ទ" មានវិសាលភាពអនុវត្តនៅគ្រប់កន្លែងឃុំឃាំងជនទាំងឡាយ ដែលត្រូវបានដកហូតសេរីភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុញ្ញាតឲ្យ "គ.ជ.ប.ទ" ទៅត្រួតពិនិត្យមើលកន្លែងណាដែលស្ថិតក្នុងដែនសមត្ថកិច្ចនិងការគ្រប់គ្រងរបស់ខ្លួនចំពោះជនទាំងឡាយដែលត្រូវបានឬអាចត្រូវបានដកហូតសេរីភាព។

**មាត្រា ៤._**

- ទារុណកម្មមានន័យថា អំពើទាំងឡាយណាដែលនាំឲ្យមានការឈឺចាប់ ឬវេទនាយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្ត ដែលបានបង្ករឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជាការទាញយកព័ត៌មាន ឬចម្លើយសារភាពពីជននោះ។ មិនមែនរាល់ការឈឺចាប់ ឬការវេទនាសុទ្ធតែត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្មនោះទេ គឺត្រូវឲ្យមានធាតុផ្សំសំខាន់ៗមួយចំនួនដូចខាងក្រោម ៖
  - ការឈឺចាប់ ឬការវេទនាបង្ករឡើងដោយចេតនា ឬជាប្រព័ន្ធមិនមែន ដោយសារតែឧប្បត្តិហេតុ និងបណ្តាលមកពីការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ឡើយ
  - ការឈឺចាប់ ឬការវេទនាត្រូវបានបង្ករឡើងដោយមន្ត្រីសាធារណៈណាម្នាក់ដូចជា មន្ត្រីនគរបាលមន្ត្រីពន្ធនាគារ ឬមន្ត្រីយោធា ឬដោយមានការព្រមព្រៀង ឬតាមការញុះញង់ពីមន្ត្រីទាំងនោះ
  - ការឈឺចាប់ ឬការវេទនា ដែលបង្កឡើងដើម្បីទាញយកព័ត៌មាន ឬការបង្ខំឲ្យឆ្លើយសារភាពធ្វើទណ្ឌកម្ម បំភិតបំភ័យបង្ខិតបង្ខំ ឬដើម្បីហេតុផលណាមួយ ដោយផ្អែកលើការរើសអើងណាមួយ
- ការដកហូតសេរីភាពមានន័យថា រាល់ទម្រង់ នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ ឬការដាក់ជនណាម្នាក់នៅក្នុងកន្លែងឃុំឃាំងដែលគេមិនអនុញ្ញាតឲ្យជននោះចាកចេញតាមចិត្ត ដោយធ្វើតាមបញ្ជារបស់អាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរដទៃទៀត។

## ជំពូកទី ២
## អំពីសមាសភាព

**មាត្រា ៥._**

សមាសភាព "គ.ជ.ប.ទ" ត្រូវជាឥស្សរជនទាំងពីរភេទ ដែលមានសមត្ថភាពជំនាញវិជ្ជាជីវៈណាមួយដូចខាងក្រោម ៖

- មានបទពិសោធន៍ ផ្នែកសិទ្ធិមនុស្សជាតិ ឬអន្តរជាតិ
- មានជំនាញផ្នែកច្បាប់ ពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- វេជ្ជបណ្ឌិតជំនាញខាងការធ្វើកោសល្យវិច័យ
- ចិត្តវិទ្យា និងវេជ្ជបណ្ឌិត ផ្នែកវិកលចរិត
- ធ្លាប់មានបទពិសោធន៍វិជ្ជាជីវៈ ផ្នែកគោលនយោបាយ រដ្ឋបាលពន្ធនាគារ
- មានបទពិសោធន៍វិជ្ជាជីវៈទាក់ទងនឹងការធ្វើទស្សនកិច្ចត្រួតពិនិត្យនៅតាមកន្លែងឃុំឃាំង
- មានបទពិសោធន៍ក្នុងការងារសង្គមកិច្ច។

**មាត្រា ៦._**

សមាសភាព "គ.ជ.ប.ទ" ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មិនដែលមានទោសមជ្ឈិម ឬឧក្រិដ្ឋ
- មានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល
- មានបទពិសោធន៍ការងារចាប់ពី ១០(ដប់)ឆ្នាំឡើង
- មានអាយុយ៉ាងតិច ៣៥(សាមសិបប្រាំ)ឆ្នាំ

**មាត្រា ៧._**

សមាជិក "គ.ជ.ប.ទ" មានចំនួន ០៩ (ប្រាំបួន)រូប ជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច ដាក់ថ្វាយព្រះមហាក្សត្រធ្វើការតែងតាំងដោយព្រះរាជក្រឹត្យ។

- ប្រធាន "គ.ជ.ប.ទ" ត្រូវបានផ្តល់ឋានៈស្មើរដ្ឋមន្ត្រី
- អនុប្រធាន "គ.ជ.ប.ទ" ត្រូវបានផ្តល់ឋានៈស្មើរដ្ឋលេខាធិការ
- សមាជិក "គ.ជ.ប.ទ" ត្រូវបានផ្តល់ឋានៈស្មើអនុរដ្ឋលេខាធិការ។

**មាត្រា ៨._**

ប្រាក់បំណាច់របស់ប្រធាន អនុប្រធាន សមាជិក និងមន្ត្រីលេខាធិការដ្ឋាន "គ.ជ.ប.ទ" ត្រូវបានកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៩._**

សមាជិកទាំងអស់នៃ "គ.ជ.ប.ទ" ត្រូវបានតែងតាំងសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ។ អាណត្តិនេះអាចត្រូវបន្តមួយអាណត្តិទៀតបាន។ សមាជិក "គ.ជ.ប.ទ" ក្នុងអាណត្តិត្រូវបំពេញមុខងាររហូតដល់សមាជិកថ្មីចូលមកជំនួស។

រយៈពេល ៦ (ប្រាំមួយ)ខែ មុនចប់អាណត្តិនិមួយៗ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជ្រើសរើសសមាជិក "គ.ជ.ប.ទ" ថ្មីមកជំនួស។

**មាត្រា ១០._**

សមាជិក "គ.ជ.ប.ទ" មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង។

មាត្រា ១១._

ប្រធាន អនុប្រធាន និងសមាជិក "គ.ជ.ប.ទ" អាចបញ្ចប់ពីមុខតំណែងក្នុងករណីណាមួយដូចខាងក្រោម៖

- លាលែង
- បញ្ឈប់ពីការងារ

- បាត់បង់សមត្ថភាពការងារ

- មរណភាព

ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវស្នើតែងតាំងជំនួសក្នុងរយៈពេល ៣០ *(សាមសិប)*ថ្ងៃ យ៉ាងយូរ ប្រសិនបើអាណត្តិរបស់ "គ.ជ.ប.ទ" នៅសល់រយៈពេលលើសពី ៦ (ប្រាំមួយ)ខែ។

**មាត្រា ១២._**

ប្រធាន "គ.ជ.ប.ទ" សម្របសម្រួលការងាររួម និងដឹកនាំអង្គប្រជុំ។ ក្នុងករណីដែលប្រធាន "គ.ជ.ប.ទ" អវត្តមាន ប្រធាន "គ.ជ.ប.ទ" ត្រូវចាត់តាំងអនុប្រធានមួយរូបជាប្រធានស្ដីទី ដឹកនាំ "គ.ជ.ប.ទ" ជំនួស។

## ជំពូកទី ៣

## អំពីតួនាទី ភារកិច្ច និងសិទ្ធិ

**មាត្រា ១៣._**

"គ.ជ.ប.ទ" មានតួនាទី ភារកិច្ច និងសិទ្ធិដូចតទៅះ

- ធ្វើសេនាធិការឲ្យរាជរដ្ឋាភិបាល លើការងារប្រឆាំងទារុណកម្មអំពើឃោរឃៅអំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ទណ្ឌកម្ម ឬបន្ទាបបន្ថោក
- កសាងយុទ្ធសាស្ត្រ និងរៀបចំផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង របស់ "គ.ជ.ប.ទ"
- ត្រួតពិនិត្យយ៉ាងទៀងទាត់នូវប្រព្រឹត្តកម្មលើជន ដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅតាមកន្លែងឃុំឃាំងនានា ដើម្បីការពារជនទាំងនោះពីទារុណកម្ម អំពើឃោរឃៅអំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ទណ្ឌកម្ម ឬបន្ទាបបន្ថោក
- អប់រំ ផ្សព្វផ្សាយ បណ្ដុះបណ្ដាលស្ដីពីអនុសញ្ញា និងពិធីសារបន្ថែមប្រឆាំងទារុណកម្មជាសាធារណៈ និងតាមមុខសញ្ញានីមួយៗ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលមានចែងក្នុងអនុសញ្ញាប្រឆាំងទារុណកម្ម និងពិធីសារបន្ថែម
- ទទួល និងធ្វើទំនាក់ទំនងជាមួយអនុគណៈកម្មាធិការបង្ការរបស់អង្គការសហប្រជាជាតិ ដើម្បីផ្ដល់លទ្ធភាពឲ្យអនុគណៈកម្មាធិការនេះអាចបំពេញអាណត្តិការងាររបស់ខ្លួនបានស្របតាមមាត្រា២០ នៃពិធីសារបន្ថែម
- ជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ឲ្យប្រព្រឹត្តលើជនដែលត្រូវបានសង្ស័យ ឬជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ដោយគោរពឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា
- ផ្ដល់អនុសាសន៍ជូនអាជ្ញាធរពាក់ព័ន្ធ ក្នុងគោលបំណងកែលម្អប្រព្រឹត្តកម្ម និងស្ថានភាពរបស់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព និងដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្មស្របតាមស្មារតី នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងអនុគណៈកម្មាធិការបង្ការរបស់អង្គការសហប្រជាជាតិ
- សិទ្ធិធ្វើទស្សនកិច្ចត្រួតពិនិត្យពន្ធនាគារ ឬមជ្ឈមណ្ឌលអប់រំកែប្រែទាំងពិរុទ្ធជន និងទណ្ឌិតមណ្ឌលឃុំខ្លួនអនីតិជន កន្លែងឃុំខ្លួនបណ្ដោះអាសន្នរបស់នគរបាលយុត្តិធម៌ មន្ទីរពេទ្យវិកលចរិត

មណ្ឌលសុខភាពផ្លូវចិត្ត មជ្ឈមណ្ឌលស្តារនីតិសម្បទា សង្គមកិច្ច មជ្ឈមណ្ឌលបន្សាបគ្រឿងញៀន ឬមណ្ឌលអប់រំផ្សេងទៀត ទូទាំងប្រទេស

- សិទ្ធិទទួលបានព័ត៌មានអំពីចំនួនជន ដែលត្រូវបានដកហូតសិទ្ធិសេរីភាព នៅតាមទីកន្លែងឃុំឃាំង ស្ថានភាព នៃការឃុំឃាំង និងការប្រព្រឹត្តកម្មលើជនទាំងនោះផង
- សិទ្ធិធ្វើសេចក្តីស្នើ និងធ្វើសេចក្តីសង្កេតលើច្បាប់ ដែលមានស្រាប់ ឬសេចក្តីព្រាងច្បាប់នានា
- ពិនិត្យ អនុម័ត និងគ្រប់គ្រងគម្រោងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញា និងពិធីសារបន្ថែមប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច មុននឹងផ្ញើទៅអង្គការសហប្រជាជាតិ។
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពដែល "គ.ជ.ប.ទ" បានបំពេញ ផ្ញើជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី ៤
## អំពីនីតិវិធី នៃការអនុវត្តការងារ

**មាត្រា ១៤._**

ការប្រើប្រាស់អំណាចរបស់ "គ.ជ.ប.ទ" មិនត្រូវប៉ះពាល់ដល់អំណាចតុលាការឡើយ។

**មាត្រា ១៥._**

សមាជិក "គ.ជ.ប.ទ" មានឯករាជ្យភាពមុខងារ ដោយមិនទទួលយកការបញ្ជាណែនាំពីអាជ្ញាធរថ្នាក់ណាមួយឡើយ ក្នុងការបំពេញកិច្ចការរបស់ខ្លួន។

**មាត្រា ១៦._**

ជនណាមួយដែលមានបំណងចង់ឲ្យមានការគោរពសិទ្ធិជាមូលដ្ឋាន អាចជូនដំណឹងទៅ "គ.ជ.ប.ទ" អំពីកន្លែងដែលមានហេតុការណ៍ផ្សេងៗ ឬអំពីស្ថានភាពនៃការឃុំឃាំងជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព បើយល់ឃើញថាចាំបាច់។

**មាត្រា ១៧._**

ប្រធាន "គ.ជ.ប.ទ" ត្រូវរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួនជាទៀងទាត់ប្រចាំត្រីមាស ក្នុងករណីចាំបាច់ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។

របៀបរបបការងាររបស់ "គ.ជ.ប.ទ" ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៨._**

ប្រធាន "គ.ជ.ប.ទ" មានសិទ្ធិទាក់ទង និងអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធនានាឲ្យចូលរួមប្រជុំពិគ្រោះយោបល់ និងបំភ្លឺលើបញ្ហាទាំងឡាយ ដែលអាចទាក់ទងនឹងក្របខ័ណ្ឌការងាររបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម។

**មាត្រា ១៩._**

"គ.ជ.ប.ទ" អាចមានជំនួយការ ទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ អន្តរជាតិមួយចំនួនតាមការចាំបាច់ដើម្បីការងារ "គ.ជ.ប.ទ"។

**មាត្រា ២០._**

"គ.ជ.ប.ទ"ត្រូវមានលេខាធិការដ្ឋានមួយ ដែលជាអង្គភាពប្រតិបត្តិសម្រាប់ដំណើរការការងារប្រចាំថ្ងៃ។ មន្ត្រី នៃលេខាធិការដ្ឋាន ត្រូវជាមន្ត្រីដែលមានក្របខ័ណ្ឌស្រាប់។

លេខាធិការដ្ឋាន នៃ "គ.ជ.ប.ទ" ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអនុប្រធានលេខាធិការដ្ឋាននៃ "គ.ជ.ប.ទ" ត្រូវតែងតាំងដោយអនុក្រឹត្យ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន "គ.ជ.ប.ទ" ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ២១._**

សមាជិក "គ.ជ.ប.ទ" និងមន្ត្រី នៃលេខាធិការដ្ឋានរបស់ "គ.ជ.ប.ទ" ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ ចំពោះហេតុការណ៍ ទង្វើ ឬព័ត៌មាន ដែលខ្លួនបានដឹងក្នុងពេលបំពេញមុខនាទីលើកលែងតែហេតុការណ៍ ទង្វើ ឬព័ត៌មាន ដែលសម្រាប់ធ្វើរបាយការណ៍ អនុសាសន៍ និងមតិដែលត្រូវបញ្ចេញ ដោយអនុលោមតាមអនុសញ្ញាប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ទណ្ឌកម្ម ឬបន្ទាបបន្ថោក និងពិធីសារបន្ថែម នៃ អនុសញ្ញានេះ។

## ជំពូកទី ៥
## អំពីរូបសញ្ញា និងត្រា

**មាត្រា ២២._**

"គ.ជ.ប.ទ" មានរូបសញ្ញា និងត្រាដោយឡែករបស់ខ្លួន។ រូបសញ្ញា និងត្រារបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ត្រូវកំណត់ក្នុងអនុក្រឹត្យ។

## ជំពូកទី ៦
## អំពីប្រភពធនធាន

**មាត្រា ២៣._**

ធនធានសម្រាប់ដំណើរការ "គ.ជ.ប.ទ" ផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក ក្នុងឧបសម្ព័ន្ធនៃកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ និងមូលនិធិដៃគូអភិវឌ្ឍផ្សេងទៀត។ ប្រធាន "គ.ជ.ប.ទ" ជាអាណាបក្សទទួលសិទ្ធិ។

**មាត្រា ២៤._**

ប្រធាន "គ.ជ.ប.ទ" មានសិទ្ធិទទួលគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីថវិកាជាតិ និងពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀតដើម្បីធានាការអនុវត្តដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៥._**

អនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិ ដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម និងបទប្បញ្ញត្តិនានាទៀតដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ២៦._

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០១៧*

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរស. ១៧០៩. ៦២៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**សម្តេចក្រឡាហោម ស ខេង**

លេខ: ៦២៥ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**